របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ
និងអគ្គលេខាធិការដ្ឋាន
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមករា ឆ្នាំ២០២០

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

ដោយ ឯកឧត្តម **ឈឹម យិនដាវ៉ែត**
អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

មាតិកា

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំខែមករា

៤. ភាពប្រសើរ និងភាពប្រឈម

៥. ជំហានបន្តសម្រាប់ខែបន្ទាប់

១.
សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

- អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅ២០២០ របស់ អ.ជ.ប.ជ.អ
- អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅ២០២០ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ
- អញ្ជើញចូលរួមមិទ្ធិញ្ញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤១ ថ្ងៃជ័យជម្នះ៧មករា
- ទទួលជួបជាមួយគណៈប្រតិភូ ក្រុមប្រឹក្សាកិបាលសម្របសម្រួលកម្មវិធីអង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ទទួលជួបជាមួយទីប្រឹក្សាបច្ចេកទេសអង្គការ FHI360 ពីការិយាល័យកណ្តាលនៅសហរដ្ឋអាមេរិក ស្វែងយល់ពីឧបសគ្គនានាជាពិសេសតម្រូវការសក្តិកម្មសម្រាប់គាំទ្រដល់វិធីសាស្ត្រផ្សេងៗ ក្នុងទិសដៅឆ្ពោះទៅរក្សាចីរភាពនៃការងារប្រយុទ្ធនឹងជំងឺអេដស៍
- ទទួលជួបអ្នកស្រីប្រធានអង្គការ UNAIDS នៅកម្ពុជា និងសហការី ដើម្បីពិភាក្សាពីការត្រៀមទទួលគណៈប្រតិភូរបស់ក្រុមប្រឹក្សាភិបាលនៃអង្គការUNAIDS ចុះមកពិនិត្យមើលស្ថានភាពនិងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់កម្ពុជា

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្ទៃក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្ទៃក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម ង៉ា ផលា

- ដឹកនាំកិច្ចប្រជុំប្រចាំ ត្រីមាស ក្រុមការងារបច្ចេកទេសថ្នាក់ខេត្តក្នុងការឆ្លើយតបអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងមេរោគអេដស៍ សម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈម នៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង ដែលរៀបចំដោយគម្រោង Linkages របស់អង្គការ fhi360
- ដឹកនាំកិច្ចប្រជុំជាមួយតំណាងUNAIDS team អំពីការធ្វើការវាយតម្លៃ នៃ Optima HIV Allocative Efficiency Model
- ចូលរួមប្រជុំក្រុមការងារចម្រុះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ពិនិត្យការប្តូរវេននៃសហប្រធានពីខាងដៃគូ កែសម្រួលតួនាទីភារកិច្ចរបស់ក្រុមការងារជាថ្មី ការត្រៀមចូលរួមធ្វើសំណើថវិកាមូលនិធិសកលជុំថ្មី
- ចូលរួមអម ឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងជំនួបជាមួយអ្នកស្រីប្រធាន UNAIDS នៅកម្ពុជា និងសហការី ដើម្បីពិភាក្សាពីការត្រៀមទទួលគណៈប្រតិភូរបស់ក្រុមប្រឹក្សាភិបាលនៃអង្គការUNAIDS ចុះមកពិនិត្យមើលស្ថានភាពនិងការឆ្លើយតបអេដស៍របស់កម្ពុជា

- ចូលជួបជាមួយ ឯ.ឧ. សាស្ត្រាចារ្យ អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល ពិភាក្សាអំពីការអនុវត្តវិធានការទី៣នៃ ស.ជ.ណ. ២១៣ ស្តីពីការសមាហរណកម្មការងារអេដស៍ក្នុងកញ្ចប់ការងាររបស់មូលនិធិសមធម៌
- ជួបរាយការណ៍ការងារជំនួបជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីប្រឹក្សាអង្គការUNAIDS និង ឯ.ឧ. រដ្ឋលេខាធិការក្រសួងសុខាភិបាល ដល់ ឯកឧត្តមទេសរដ្ឋមន្ត្រី
- អម ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលជួបជាមួយទីប្រឹក្សាបច្ចេកទេសអង្គការ FHI360 ពីការិយាល័យកណ្តាលនៅសហរដ្ឋអាមេរិក ស្វែងយល់ពីឧបសគ្គនានាជាពិសេសតម្រូវការសក្តីកម្មសម្រាប់គាំទ្រដល់វិធីសាស្ត្រផ្សេងៗ ក្នុងទិសដៅឆ្ពោះទៅរក្សាចីរភាពនៃការងារប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមកិច្ចពិភាក្សាថ្នាក់ជាតិរៀបចំគម្រោងសំណើថវិកាតំបន់ (ROP) របស់ PEPFAR សម្រាប់ឆ្នាំ២០២០
- ចូលរួមជាមួយគណៈកម្មការសម្របសម្រួលថ្នាក់ប្រទេសនៃមូលនិធិសកល ក្នុងកិច្ចពិភាក្សាថ្នាក់ប្រទេសស្តីពីការរៀបចំគម្រោងសំណើថវិកាមូលនិធិសកលជុំថ្មី ២០២១ ដល់២០២៣។

ឯកឧត្តម តែង គន្ធី

- ជួបពិភាក្សាជាមួយសមាជិកគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងទេសចរណ៍ ការពារជាតិ អគ្គបញ្ជាការដ្ឋាន
- រៀបចំប្រព័ន្ធទំនាក់ទំនងព័ត៌មាន
- ជួបពិភាក្សាជាមួយអង្គការ MHSS លើការងារក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ

ឯកឧត្តម រស់ សីលវ៉ាត់

- ពិនិត្យ និងជូនយោបល់កែសម្រួលរបាយការណ៍បច្ចេកទេសប្រចាំសប្តាហ៍ទី៣ ខែធ្នូ ២០១៩
- ពិនិត្យ និងជូនយោបល់កែសម្រួលរបាយការណ៍សកម្មភាពប្រចាំខែវិច្ឆិកា ២០១៩
- ចូលរួមប្រជុំក្រុមការងារគ្រប់គ្រងមូលនិធិ ពិនិត្យមើលផែនការសកម្មភាពក្នុងឆ្នាំ២០២០ និងការត្រៀមលក្ខណៈចូលរួមក្នុងការសរសេរសំណើមូលនិធិសកលជុំថ្មី
- ចូលរួមប្រជុំប្រចាំខែរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលនៅក្រសួងសុខាភិបាល
- ទទួលជួបជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះប្រមូលទិន្នន័យថវិកាស្មើ និងប្រើប្រាស់ក្នុងស្ថាប័ន អ.ជ.ប.ជ.អ. សម្រាប់ជាមូលដ្ឋានផ្តល់សក្តីកម្មដល់មូលនិធិសកលអំពីបរិមាណបដិភាគនៃថវិកាជាតិជាមួយគម្រោងមូលនិធិសាកលក្នុងដំបូងឆ្នាំ ២០១៨ ដល់២០២០
- ទទួលជួបជាមួយទីប្រឹក្សាបច្ចេកទេសរបស់អង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា ក្នុងការសិក្សាស្រាវជ្រាវអំពីតម្រូវការវិនិយោគសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍តាមគំរូ OPTIMA

- ចូលរួមជាមួយ ឯ.ឧ. អនុប្រធានទី ផលា ចូលជួបជាមួយ ឯ.ឧ. សាស្ត្រាចារ្យ អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល ពិភាក្សាអំពីការអនុវត្តវិធានការទី៣នៃ ស.ជ.ណ. ២១៣ ស្តីពីការសមាហរណកម្ម ការងារអេដស៍ក្នុងកញ្ចប់ការងាររបស់មូលនិធិសមធម៌
- ចូលរួមជាមួយ ឯ.ឧ. អនុប្រធានទី ផលា ជួបរាយការណ៍ការងារជំនួបជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីប្រឹក្សាអង្គការ UNAIDS និង ឯ.ឧ. រដ្ឋលេខាធិការក្រសួងសុខាភិបាល
- ពិនិត្យរបាយការណ៍ប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ ខែមករា ឆ្នាំ២០២០
- ពិនិត្យ និងកែសម្រួលរបាយការណ៍សកម្មភាពប្រចាំខែធ្នូ ឆ្នាំ២០១៩
- ចូលរួមអម ឯ.ឧ. ប្រធានក្នុងជំនួបជាមួយ អ្នកស្រីប្រធានUNAIDS នៅកម្ពុជា និងសហការី ដើម្បីពិភាក្សាពីការត្រៀមទទួលគណៈប្រតិភូរបស់ក្រុមប្រឹក្សាភិបាលនៃអង្គការ UNAIDS
- ពិនិត្យ និងកែសម្រួលរបាយការណ៍សកម្មភាពប្រចាំខែធ្នូ ឆ្នាំ២០១៩

- ចូលរួមប្រជុំក្រុមការងារចម្រុះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ពិនិត្យការប្តូរវេននៃសហប្រធានពីខាងដៃគូ កែសម្រួល តួនាទីភារកិច្ចរបស់ក្រុមការងារជាថ្មី ការត្រៀមចូលរួមធ្វើសំនើថវិកាមូលនិធិសាកលជុំថ្មី ការជាក់ស្តែងរបស់ អ.ជ.ប.ជ.អ
- ចូលរួមជាមួយឯ.ឧ. អនុប្រធានទា ផលា ទទួលជួបជាមួយទីប្រឹក្សាបច្ចេកទេសអង្គការ FHI360 ពីការិយាល័យកណ្តាលនៅសហរដ្ឋអាមេរិក ស្វែងយល់ពីឧបសគ្គនានាជាពិសេសតម្រូវការសក្តីកម្មសម្រាប់គាំទ្រដល់វិធីសាស្ត្រផ្សេងៗ ក្នុងទិសដៅឆ្ពោះទៅរក្សាចីរភាពនៃការងារប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមជាមួយ ក្រុមការងារ PEPFAR ក្នុងកិច្ចពិភាក្សាថ្នាក់ជាតិរៀបចំគម្រោងសំណើថវិកាតំបន់ (ROP) របស់ PEPFAR សម្រាប់ឆ្នាំ២០២០
- ចូលរួមជាមួយគណៈកម្មការសម្របសម្រួលថ្នាក់ប្រទេសនៃមូលនិធិសកល ក្នុងកិច្ចពិភាក្សាថ្នាក់ប្រទេសស្តីពីការរៀបចំគម្រោងសំណើថវិកាមូលនិធិសកលជុំថ្មី ២០២១ ដល់២០២៣
- ដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីជំនាញធ្វើសេចក្តីព្រាងផែនការវិនិយោគបីឆ្នាំរំកិល ២០២១ ដល់២០២៣ របស់ អ.ជ.ប.ជ.អ

ករណីដោយឡែក

ចំពោះ ឯកឧត្តម លោកជំទាវ អនុប្រធាន អ.ជ.ប.ជ.អ ដែលអគ្គលេខាធិការដ្ឋានពុំទាន់ទទួលបានរបាយការណ៍នាពេលនេះ នឹងដាក់បញ្ចូលក្នុងរបាយការណ៍ពេញលេញខែមករាក្រោយទទួលបាន។

២.

សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការ

- ចុះបេសកកម្មស្វែងយល់ការអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំប្រចាំ ត្រីមាស ក្រុមការងារបច្ចេកទេសថ្នាក់ខេត្តក្នុងការឆ្លើយតបអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងមេរោគអេដស៍ សម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈម នៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង ដែលរៀបចំដោយគម្រោង Linkages របស់អង្គការ FHI360
- កិច្ចប្រជុំជាមួយតំណាងក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះប្រមូលទិន្នន័យថវិកាស្នើ និងប្រើប្រាស់ក្នុងស្ថាប័ន អ.ជ.ប.ជ.អ. សម្រាប់ជាមូលដ្ឋានផ្តល់សក្តីកម្មដល់មូលនិធិសាកលអំពីបរិមាណបដិភាគនៃថវិកាជាតិជាមួយគម្រោងមូលនិធិសកលក្នុងដំបូងឆ្នាំ ២០១៨ ដល់២០២០
- ចូលរួមកិច្ចប្រជុំជាមួយតំណាងUNAIDS team អំពី ការធ្វើការវាយតម្លៃ នៃ Optima HIV Allocative Efficiency Model

- ដឹកនាំកិច្ចប្រជុំពិនិត្យការងារគម្រោងផ្តួចផ្តើមភាពជាដៃគូនៅសហគមន៍សម្រាប់ក្រុមប្រឈមមុខខ្ពស់ (MCPI)
- ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ ប្រចាំត្រីមាសទី៤ ដែលជាក្រុមប្រជាជនគន្លឹះដោយមានការចូលរួមពីតំណាងអង្គការពាក់ព័ន្ធ រួមមាន: KHANA, AHF, Fhi360, MHC, MEC, WNU, MH55 ដោយមានបទបង្ហាញពិភាក្សាលើលទ្ធផល និងការងារប្រឈម ចំនួន៤ ផ្តោតលើស្ថានភាពបុរសរួមភេទជាមួយបុរស (MSM) និងក្រុមបំប្លែងភេទ (TG)
- ទទួលជួបពិភាក្សាការងារជាមួយ លោកប្រធានអង្គការ KHANA ស្វែងយល់ពីការលទ្ធផលការងារកន្លងមក និងទិសដៅខាងមុខក្នុងការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ របស់អង្គការ
- ទទួលជួបជាមួយតំណាងទីចាត់ការសុខាភិបាលនៃអគ្គមេបញ្ជាការដ្ឋានកងខេមរភូមិន្ទ
- ទទួលជួបពិភាក្សាការងារជាមួយ លោកប្រធានអង្គការ RHAC ស្វែងយល់ពីការលទ្ធផលការងារកន្លងមក និងទិសដៅខាងមុខក្នុងការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ របស់អង្គការ
- ទទួលជួបពិភាក្សាជាមួយ HP+ អំពីការវិវត្តនៃការអនុវត្ត ស.ជ.ណ ២១៣

- ពិនិត្យរៀបចំកែសម្រួលទិន្នន័យសង្ខេបស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា ឆ្នាំ២០១៨ (Snapshot 2018 on HIV and AIDS in Cambodia)
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីការបង្កបរិយាកាសអំណោយផលសម្រាប់ក្រុមប្រជាជនគន្លឹះ ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ក្រោមគម្រោងមូនិធិសកល។
- ចូលរួមកិច្ចប្រជុំ ក្រុមការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ប្រយុទ្ធនឹងជំងឺអេដស៍ (GDJ) លើកទី១ ឆ្នាំ ២០២០
- ចូលរួមអម ឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងជំនួបជាមួយអ្នកស្រីប្រធាន UNAIDS នៅកម្ពុជា និងសហការី ដើម្បីពិភាក្សាពីការត្រៀមទទួលគណៈប្រតិភូរបស់ក្រុមប្រឹក្សាភិបាលនៃអង្គការUNAIDS ចុះមកពិនិត្យមើលស្ថានភាពនិងការឆ្លើយតបអេដស៍របស់កម្ពុជា
- ពិនិត្យសម្រេចលើរបាយការណ៍ក្រុមប្រឹក្សាបច្ចេកទេស របាយការណ៍បច្ចេកទេសប្រចាំខែ របាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែរបស់ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន និងពិនិត្យរបាយការណ៍របស់មន្ត្រីទាំងអស់នៃអគ្គលេខាធិការដ្ឋាន

- ប្រជុំជាមួយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ រៀបចំរបៀបវារៈសិក្ខាសាលាស្តីពីការលើកទិសដៅផែនការសកម្មភាពឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តស្ទឹងត្រែង
- ចូលរួមកិច្ចប្រជុំពិភាក្សាធ្វើសេចក្តីព្រាងផែនការវិនិយោគបីឆ្នាំរំកិល ២០២១ ដល់២០២៣ របស់ អ.ជ.ប.ជ.អ
- ដឹកនាំកិច្ចប្រជុំរួមប្រចាំខែអគ្គលេខាធិការដ្ឋាន
- ដឹកនាំកិច្ចប្រជុំប្រចាំខែ មួយលើក
- ដឹកនាំកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ បួនលើក ជាទៀងទាត់
- ពិនិត្យ ផ្តល់យោបល់លើការងាររដ្ឋបាល និងហិរញ្ញវត្ថុប្រចាំថ្ងៃ។

អគ្គលេខាធិការដ្ឋាន

ឯកឧត្តម លោកជំទាវអគ្គលេខាធិការរងទាំងបួនរូប បានបំពេញការងារជួយ អគ្គលេខាធិការ តាមការបែងចែកភារកិច្ច និងមានសកម្មភាព លទ្ធផលការងារដូចក្នុងរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ដែលបានគោរពជូន។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

- បានប្រជុំផ្ទៃក្នុងនាយកដ្ឋានប្រចាំសប្តាហ៍ចំនួន៣លើក
- បានរៀបចំលិខិតទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីស្នើសុំការអនុញ្ញាតជូនឯកឧត្តមទេសរដ្ឋមន្ត្រី ដឹកនាំគណៈប្រតិភូកម្ពុជាចំនួន ៣នាក់ទៅចូលរួមសន្និសីទអន្តរជាតិស្តីពីជំងឺអេដស៍ លើកទី ២៣ នៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ និងអូកឡេន ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៦ ដល់១០ ខែកក្កដា ឆ្នាំ២០២០
- បានរៀបចំលិខិតបញ្ជាបេសកកម្មសម្រាប់ទៅចូលរួមសិក្ខាសាលាស្តីពីការលើកទិសដៅផែនការសកម្មភាពឆ្នាំ ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តស្វាយរៀង
- បានរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ និងខែ របស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងបានសរុបបញ្ជីវត្តមានសប្តាហ៍ និងខែ ដាក់ជូនថ្នាក់ដឹកនាំ
- បានស្នើសុំខ្ចីថវិការដ្ឋទេយ្យដុំទី១ ឆ្នាំ២០២០ ចំនួន៨០% ពីអគ្គនាយកដ្ឋានរតនាគារជាតិ
- បានដកថវិកា ២៦៣,៨០៩,៦០០ ពីអគ្គនាយករតនាគារចាតិយកមកប្រើប្រាស់
- បានរៀបចំ និងដាក់ឯកសារស្នើសុំបង្កើតដុំរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២០ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំរបាយការណ៍ចំណូល ចំណាយ សៀវភៅបេឡា សៀវភៅធំ ទិន្នានុប្បវត្តិ (តារាង តុល្យភាព) ដើម្បីផ្ញើជូនអគ្គនាយកដ្ឋានរតនាគារជាតិ

- បានលើកគម្រោងចំណាយសម្រាប់រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស លើកទី១ ឆ្នាំ២០២០ ដែលគ្រោងនឹងធ្វើឡើងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០
- បានព្រាងលិខិតស្នើសុំក្រសួង ស្ថាប័ន ផ្តល់សមាសភាពសមាជិកភាពក្រុមប្រឹក្សាបច្ចេកទេស ដើម្បីធ្វើបច្ចុប្បន្នភាពនៅដើមឆ្នាំ២០២០
- បានទាក់ទងរកសណ្ឋាគារដើម្បីរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីបញ្ជីសារពើភ័ណ្ឌ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅ ខេត្តកែប
- បានទាក់ទងរកសណ្ឋាគារដើម្បីរៀបចំទិវាអន្តរជាតិនារី ៨មីនា និងសិក្ខាសាលាស្តីពីការលើកទិសដៅផែនការសកម្មភាពឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលគ្រោងនឹងរៀបចំ នៅថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ នៅស្ទឹងត្រែង
- បានជំរុញការទទួលឯកសារបេសកកម្មដែលត្រឡប់មកពីខេត្តវិញ និងការកត់ត្រាលេខអាណត្តិ នៃឯកសារផ្ញើទេយ្យ និងបេសកកម្មចូលតារាង
- បានឡើងតារាងទូទាត់សរុបប្រាក់បេសកកម្មតាមកម្មវិធី ជំពូក៦១ ចំនួន១៦ច្បាប់ (សម្រាប់ការទូទាត់ត្រង់)
- បញ្ចប់ការបើកផ្តល់សម្ភារការិយាល័យជូនថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋាន ទាំង៤

- ចូលរួមរៀបចំចំណាយកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស លើកទី១ ឆ្នាំ២០២០ ដែលធ្វើឡើងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០
- បញ្ជាក់ និងកក់សណ្ឋាគារដើម្បីរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីបញ្ជីសារពើ ភ័ណ្ឌ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅខេត្តកែប។
- បញ្ជាក់ និងកក់សណ្ឋាគារដើម្បីរៀបចំទិវាអន្តរជាតិនារី និងសិក្ខាសាលាស្តីពីការលើក ទិសដៅផែនការសកម្មភាពឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលគ្រោងនឹងរៀបចំនៅថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ នៅខេត្តស្ទឹងត្រែង
- តាមដានឯកសារស្នើសុំបង្កើតជុំរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២០ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ

- បានប្រជុំប្រចាំខែក្នុងនាយកដ្ឋាន១លើក និងបានរៀបចំផែនការរបស់នាយកដ្ឋាន ដើម្បី លើកផែនការសកម្មភាពសម្រាប់អនុវត្តបន្ត និងពង្រឹងការៈកិច្ចទទួលខុសត្រូវរបស់មន្ត្រីក្នុងនាយកដ្ឋាន (ទី១៤ ខែមករា)
- បានរៀបចំប្រជុំប្រចាំត្រីមាស MSM/TG និងEW (១លើក) នៅថ្ងៃទី១៥ ខែមករា
- បានធ្វើការប្រមូលទិន្នន័យពីក្រុមប្រជាជនគន្លឹះ។ បានពត៌មានថ្មីៗពីចំនួន KP, PLHIV, VCCT, MSM/TG, EW
- បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីការបង្កបរិយាកាសអំណោយផលសម្រាប់ក្រុមប្រជាជនគន្លឹះក្នុងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ សម្រាប់ថ្នាក់ខេត្ត/ រាជធានី ប្រឈមមុខខ្ពស់ នៅ អជបជអ (ទី១៧ ខែមករា ឆ្នាំ២០២០)
- បានរៀបចំ និងពិនិត្យ លើ AIDS Acronyms សម្រាប់ ដាក់ជាតុចូល ក្នុងការពិភាក្សានិងរៀបចំចងក្រង

- បានចូលរួមប្រជុំប្រចាំខែរបស់គណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន នៅកន្លែងធ្វើការ (ថ្ងៃទី២១ ខែមករា) នៅទីស្តីការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានចូលរួមប្រជុំការងារបច្ចេកទេស ជាមួយ ឯកឧត្តម អគ្គ លេខាធិការ (ថ្ងៃទី២១ ខែមករា)
- រៀបចំការងារបច្ចេកទេសសម្រាប់ចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍តាមរយៈដៃគូសហគមន៍ នៅថ្នាក់ខេត្ត
- បានរៀបចំរបាយការណ៍កិច្ចប្រជុំផ្សេងៗ សម្រាប់អគ្គលេខាធិការដ្ឋាន ថ្នាក់ដឹកនាំ និងដៃគូពាក់ព័ន្ធ។

នាយកដ្ឋានទាក់ទង និងចលនាប្រកពធនធាន

- ប្រជុំផ្ទៃក្នុងនាយកដ្ឋាន និងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែ មករា ឆ្នាំ២០២០
- ធ្វើសេចក្តីព្រាងសន្ធានុក្រមសម្រាប់ការងារអេដស៍ និងប្រជុំរៀបចំតួនាទី និងភារកិច្ចសម្រាប់មន្ត្រី
- បណ្តុះបណ្តាលបង្កើនសមត្ថភាពមន្ត្រីក្នុងនាយកដ្ឋានស្តីពីរបៀបធ្វើ Checklist និងរបាយការណ៍
- បញ្ជូនមន្ត្រីចូលរួមប្រជុំការងារមូលនិធិសកល ថ្ងៃទី១៦ ខែមករា២០២០
- រៀបចំកិច្ចប្រជុំ និងធ្វើរបាយការណ៍ក្រុមការងារបច្ចេកទេស GDJ នៅថ្ងៃទី២០ ខែមករា ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ប្រជុំពិគ្រោះយោបល់ជាមួយបណ្តាញអ្នកផ្ទុកមេរោគអេដស៍ស្តីពីការចូលរួមរបស់PLHIVក្នុងការសម្រេចឱ្យបាន សូន្យ-បី ថ្ងៃទី២១ មករាឆ្នាំ២០២០
- សម្របសម្រួលឱ្យមន្ត្រីធ្វើ Checklist សម្រាប់ ឃុំ សង្កាត់ និងខេត្តដែលនាយកដ្ឋានទាក់ទង និងចលនាប្រកពធនធានបានចុះអភិបាលកិច្ចហើយ។

នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

- បានចូលរួមប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ និងធ្វើកំណត់ហេតុប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមកិច្ចប្រជុំពិភាក្សាការងារស្តីពី Social Protection Assessment នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានចូលរួមកិច្ចប្រជុំរួមប្រចាំខែ ក្រោមការដឹកនាំរបស់អគ្គលេខាធិការ និងប្រជុំ GMC នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានបញ្ចប់សំណើសុំរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីចំណេះដឹងមូលដ្ឋាននៃមេរោគអេដស៍ និងជំងឺអេដស៍ ដល់មន្ត្រីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានបញ្ចប់ផែនការសកម្មភាព របស់អគ្គលេខាធិកាដរដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២០
- បានចូលរួមប្រជុំថ្នាក់ជាតិ ស្តីពីគម្រោងមូលនិធិសកល (Country Dialogue) កិច្ចប្រជុំ GF Funding Request Application on HIV Cambodia និងការវិភាគទិន្នន័យ បង្កើតទម្រង់សម្រាប់អនុវត្ត (scenario) ដោយប្រើប្រាស់គំរូ Optima ជាបន្ត នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS)

- បានរៀបចំបទបង្ហាញរបាយការណ៍ប្រចាំខែ និងចូលរួមប្រជុំប្រចាំខែមករាដែលដឹកនាំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស នៃ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានចូលរួមកិច្ចប្រជុំក្រុមការងារចម្រុះរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងពិនិត្យកែសម្រួលសមាជិកភាព តួនាទី និងភារកិច្ច ពិនិត្យបច្ចុប្បន្នភាព វឌ្ឍនភាព សូចនាករ JMI
- បានជួបប្រជុំជាមួយមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពី Co-financing 2020-2022 នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានប្រជុំនៅក្នុងនាយកដ្ឋាន ស្តីពីការរៀបចំតួនាទី ភារកិច្ច និងបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីក្នុងនាយកដ្ឋានទាំងអស់។

- ចូលរួមរៀបចំ និងពិនិត្យនូវព្រឹត្តិប័ត្រព័ត៌មានទិន្នន័យ ឆ្នាំ២០១៩ (Snapshot 2019)
- ពិនិត្យ និងកែសម្រួលរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆ្នាំ២០១៩
- ត្រៀមរៀបចំសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញសម្ថផលឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០ ថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ នៅខេត្តស្ទឹងត្រែង
- រៀបចំឯកសារសម្រាប់កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ ផ្ញើជូនក្រសួងផែនការ
- រៀបចំប្រមូលទិន្នន័យពីស្ថាប័នដែលពាក់ព័ន្ធដើម្បីរៀបចំរបាយការណ៍ផ្ញើជូនអង្គការសហប្រជាជាតិ(Global AIDS Monitoring for 2019)។

៣.

សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ខែមករា



- បានបញ្ចប់សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលស្តីពីការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ប្រចាំឆ្នាំ ២០១៩

- បានសម្រេច និងចាប់ផ្តើមអនុវត្តគម្រោងផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០



- បញ្ចប់សេចក្តីព្រាងទិន្នន័យសង្ខេបស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា ឆ្នាំ២០១៨ (Snapshot 2018 on HIV and AIDS in Cambodia) នឹងដាក់សុំការអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១ ឆ្នាំ២០២០ ដែលនឹងដំណើរការនៅព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្អែកនេះ។

- កំពុងដំណើរការប្រមូលចងក្រងពាក្យសម្រាប់រៀបចំសន្ទានុក្រមបច្ចេកសព្ទមេរោគអេដស៍ និងជំងឺអេដស៍ ខ្មែរ-អង់គ្លេស (LEXICON OF HIV/AIDS TERMINOLOGIES Khmer-English)

៤.

ភាពប្រសើរ និងភាពប្រឈម

គាពប្រសើរ

1. មន្ត្រីអគ្គលេខាធិការដ្ឋានបានរួមធ្វើការជាមួយគ្នា ចូលរួមពិភាក្សា ផ្តល់យោបល់ស្ថាបនា និងរៀនសូត្រពីគ្នាទៅវិញទៅមក។
2. មន្ត្រីអគ្គលេខាធិការដ្ឋានបានផ្តល់របាយការណ៍ផ្ទាល់ខ្លួនទាន់ពេលតាមការកំណត់ (អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ផ្តល់របាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ចំណែមន្ត្រីចាប់ពីអនុប្រធាននាយកដ្ឋានផ្តល់របាយការណ៍ប្រចាំខែស្តីពីសកម្មភាពការងារដែលខ្លួនបានធ្វើ និងគ្រោងសកម្មភាពសម្រាប់អនុវត្ត នៅសប្តាហ៍ និងខែបន្ទាប់)។

គាពប្រឈម

1. មន្ត្រីអគ្គលេខាធិការដ្ឋានភាគច្រើន នៅមិនទាន់បានយល់ពីសារៈសំខាន់ និងរបៀបនៃការធ្វើរបាយការណ៍ (របាយការណ៍បច្ចេកទេស និងរបាយការណ៍ផ្ទាល់ខ្លួន)។
2. គំនិតផ្តួចផ្តើម និងភាពជាម្ចាស់ការលើការងាររបស់មន្ត្រីអគ្គលេខាធិការដ្ឋានភាគច្រើននៅមានកម្រិត។
3. ការទំនាក់ទំនងជាមួយស្ថាប័នក្រៅ (ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍ សង្គស៊ីវិល និងវិស័យឯកជន) នៅមានកម្រិត។

៥. ជំហានបន្ត សម្រាប់ខែបន្ទាប់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គម្រោងផែនការសកម្មភាព និងថវិកា

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០

មគ្គុទេសក៍ភាព និងភាពជាម្ចាស់ ភាពជាដៃគូ និង ការវិនិយោគ

ដើម្បីឈានទៅបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈ

ខែមួ ឆ្នាំ២០១៩

- អនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ដើម្បីដាក់ឱ្យប្រើប្រាស់នៅទូទាំងប្រទេសនូវសង្ខេបទិន្នន័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៩ (Snapshot 2019 on HIV and AIDS in Cambodia)
- បន្តរៀបចំសន្ទានុក្រមបច្ចេកសព្ទមេរោគអេដស៍ និងជំងឺអេដស៍ ខ្មែរ-អង់គ្លេស (LEXICON OF HIV/AIDS TERMINOLOGIES Khmer-English)
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពការងារ និងការទទួលខុសត្រូវរបស់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ
- បន្តបង្កើនទំនាក់ទំនងការងារជាមួយស្ថាប័នក្រៅ ជាតិ និងអន្តរជាតិក្នុងការអនុវត្តវិធានការទាំង៦ នៃ ស.ជ.ណ. ២១៣ និងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣
- ជូនលិខិតដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ បញ្ជូនមន្ត្រីបច្ចេកទេស ដើម្បីធ្វើសេចក្តីសម្រេចតែងតាំងសមាសភាពសមាជិកក្រុមប្រឹក្សាបច្ចេកទេសជាផ្លូវការ
- រៀបចំប្រមូលទិន្នន័យដល់ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍ផ្ញើជូនអង្គការសហប្រជាជាតិ (Global AIDS Monitoring for 2019) ជូនអង្គការសហប្រជាជាតិ បានតាមការកំណត់ខែមីនា

- រៀបចំទិន្នន័យថវិកាក្នុងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០២១-២០២៣ ជូនក្រសួងផែនការបានតាមការកំណត់ខែមីនា
- អញ្ជើញមន្ត្រីបច្ចេកទេសទទួលខុសត្រូវធ្វើPIP របស់ក្រសួងផែនការមកពន្យល់នៃរបៀបធ្វើ PIP
- ត្រៀមរៀបចំការងារបច្ចេកទេស សម្រាប់ផ្តល់វគ្គបណ្តុះ បណ្តាលគ្រូបង្គោលស្តីពី បរិយាកាសគាំទ្រច្បាប់ គោលនយោបាយ និងភារៈកិច្ច ក្នុងការគាំទ្រឆ្លើយតបមេរោគអេដស៍ នឹងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ
- រៀបចំគម្រោងសកម្មភាពសម្រាប់ដាក់សំណើសុំមូលនិធិសកល ឆ្នាំ២០២១-២០២៣
- រៀបចំសិក្ខាសកម្មភាពអនុវត្តការធ្វើសមាហរណកម្មកម្មវិធីអេដស៍នៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ និងការវិនិយោគឃុំ សង្កាត់ ដោយសាកល្បងនៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីបញ្ជីសារពើភ័ណ្ឌ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅខេត្តកែប
- រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយបង្ការមេរោគអេដស៍ក្នុងទិវានៃក្តីស្រឡាញ់

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២
- ត្រៀមរៀបចំទិវាអន្តរជាតិនារី និងសិក្ខាសាលាស្តីពីការលើក ទិសដៅផែនការសកម្មភាពឆ្នាំ២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលគ្រោងនឹងរៀបចំនៅថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ នៅខេត្តស្វាយរៀង
- ការងារចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តាខេត្តមួយចំនួន
- បំពេញកិច្ចការផ្សេងៗទៀត តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

"ពង្រឹងកិច្ចការផ្ទៃក្នុង ពង្រីកទំនាក់ទំនងជាមួយស្ថាប័នក្រៅ"

សូមអរគុណ!